ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ២៩៣១ ព.ណ..ភព..

ថ្ងៃចន្ទ ១១កើត ខែអស្សុជ ឆ្នាំជូតទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០២០

## សេចក្តីជូនដំណឹង

ក្នុងនាមគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ធុរជន សហគ្រិន វិនិយោគិន និងផលិតករទាំងអស់ឲ្យបានជ្រាបថា៖ លេខាធិការពិព័រណ៍ចិន-អាស៊ាន រួមសហការជាមួយបណ្តាប្រទេសជាសមាជិកអាស៊ានទាំងអស់ នឹងបន្តរៀបចំពិព័រណ៍ពាណិជ្ជកម្មចិន-អាស៊ានលើកទី១៧ ឆ្នាំ២០២០ "The 17th China-ASEAN Expo 2020" ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៧-៣០ ខែវិច្ឆិកា ឆ្នាំ២០២០ នៅមជ្ឈមណ្ឌលសន្និសីទ និងពិព័រណ៍អន្តរជាតិ ទីក្រុងណាននីង ខេត្តក្វាងស៊ី សាធារណរដ្ឋប្រជាមានិតចិន។

ដោយស្ថានភាពនៃជំងឺកូវីដ-១៩ មិនទាន់គ្រប់គ្រងបានទាំងស្រុង និងភាពមិនច្បាស់លាស់អំពីស្ថានភាពនៃជំងឺនេះនៅឡើយ គណៈកម្មការពិព័រណ៍ចិន-អាស៊ាន នឹងរៀបចំវេទិកាពិព័រណ៍អនឡាញ សម្រាប់ក្រុមហ៊ុន សហគ្រាសកម្ពុជាដែលមានបំណងចូលរួមតាំងបង្ហាញផលិតផល និងស្វែងរកដៃគូពាណិជ្ជកម្ម និងវិនិយោគ នៅក្នុងព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ខាងលើ តាមរយៈប្រព័ន្ធអេឡិចត្រូនិក ដោយឥតគិតថ្លៃ។ គណៈកម្មការរៀបចំ នឹងផ្តល់ជូនសៀវភៅណែនាំលម្អិតអំពីនីតិវិធីប្រើប្រាស់វេទិកាពាណិជ្ជកម្មអេឡិចត្រូនិកនេះ នៅពេលក្រោយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងពាណិជ្ជកម្ម សូមអញ្ជើញធុរជន សហគ្រិន វិនិយោគិន និង ផលិតករទាំងអស់ ដែលមានបំណងចូលរួមពិព័រណ៍ពាណិជ្ជកម្មចិន-អាស៊ាន លើកទី១៧ ឆ្នាំ២០២០តាមរយៈវេទិកាអនឡាញនេះ សូមប្រញាប់រួសរាន់មកបំពេញបែបបទ នៅនាយកដ្ឋានកិច្ចការពិព័រណ៍នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម **ឲ្យបានមុនថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ជាកំណត់។**

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម តាមរយៈអាសយដ្ឋាន៖ ដីឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ទូរស័ព្ទទាក់ទង៖ ០១៧ ៧៥៩ ៥៦៧ ឬ ០៨៦ ៣៣៣ ៩៣៣ ឬ ០១២ ៦០០ ៧៧៨

០១៧ ៥៥៩ ២៧៧ ឬ ០១៧ ៤៩៥ ០៩១

អាសយដ្ឋានអ៊ីម៉ែល៖ vannameass@yahoo.com ឬ som_pitou@yahoo.com

veasna_mao@yahoo.com ឬ vitholt@yahoo.com

kdi_mpp@yahoo.com។

**សូមអរគុណ!**

KINGDOM OF CAMBODIA

Nation - Religion - King

Ministry of Commerce

N°2931.MOC....D/EA

Phnom Penh, 28 September, 2020

# ANNOUNCEMENT

On behalf of the Cambodian Inter-Ministerial Committee for Participation in the World Expo and the International Trade Exhibitions, the Ministry of Commerce has the great honor to inform to all businessmen, entrepreneurs, investors and producers that China-ASEAN Expo Secretariat in cooperation with ASEAN will be organizing "The 17th China-ASEAN Expo 2020" to be held from 27th -30th November, 2020 at Nanning International Convention and Exhibition Center, Nanning City, Guangxi Zhuang Autonomous Region of People's Republic of China.

Due to the uncertainty of COVID-19 situation, organizing committee of China-ASEAN Expo Secretariat will be organizing on-line CAEXPO during the 17th China-ASEAN Expo 2020 for Cambodian exhibitors who wish to showcase their exhibits and find their investment partners via electronic trade platform free of charge. The guidebook for on-line exhibitors will be released later.

In this regard, the Ministry of Commerce is pleased to invite all businessmen, entrepreneurs, investors and producers who have trade and investment partners in China and intend to participate in on-line CAEXPO during "The 17th China-ASEAN Expo 2020" or are looking for their trade and investment partners during the event to apply and register at Department of Exhibition Affairs, General Directorate of Trade Promotion of the Ministry of Commerce **no later than 28th October 2020**.

For further information, please contact the Department of Exhibition Affairs, General Directorate of Trade Promotion, Ministry of Commerce at Lot No. 19-61, Russian Federation Blvd, Phum Toek Thla, Sangkat Toek Thla, Khan Sen Sok, Phnom Penh, Cambodia.

Tel : 017 759 567 / 086 333 933 / 012 600 778 / 017 559 277/ 017 495 091

E-mail: vannameass@yahoo.com / sorn_pitou@yahoo.com / veasna_mao@yahoo.com
vitholt@yahoo.com / kdi_mpp@yahoo.com

Thank you!